virak2, Dana

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## តាងនាមប្រជារាស្ត្រខ្មែរ

**សាលាព្រហ្មទណ្ឌ**
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ:៥៥១
ចុះថ្ងៃទី០៩-៦-២០១៤
**សាលដីកាព្រហ្មទណ្ឌ**
លេខ: ៧០ "ក្រ W ញ"
ចុះថ្ងៃទី២០-១០-២០១៤

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាម ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើ តាម ព្រះរាជក្រម លេខ:នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ៣០-កញ្ញា-២០១៤ ម៉ោង៨:០០នាទីព្រឹក ដោយមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងស្របទោសនៃរឿងក្តីព្រហ្មទណ្ឌលេខ:៥៥១ ចុះថ្ងៃទី០៩-៦-២០១៤ របស់ សាលាឧទ្ធរណ៍ ដែលមាន:

១-ទណ្ឌិតឈ្មោះ: [redacted] **សំណាង** ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់លេខ: [redacted] មុខរបរនៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះ:លេខ [redacted] ឪពុកឈ្មោះ: [redacted] "ស" ម្តាយឈ្មោះ: [redacted] "រ" នៅរស់ ។

២-ទណ្ឌិតឈ្មោះ: [redacted] **ទីទីន** ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់ [redacted] ទីលំនៅសព្វថ្ងៃផ្ទះ:លេខ [redacted] ឪពុកឈ្មោះ: [redacted] "ស" ម្តាយឈ្មោះ: [redacted] "រ" នៅរស់ ។

-បច្ចុប្បន្នទណ្ឌិតទាំងពីរនាក់កំពុងឃុំខ្លួន នៅមណ្ឌលអប់រំកែប្រែទី១(ម១)

-មានលោកស្រី [redacted] **សិរី** ជាមេធាវីការពារក្តីឲ្យទណ្ឌិតឈ្មោះ: [redacted] សំណាង និងឈ្មោះ: [redacted] ទីទីន។

ទណ្ឌិតរូបនេះត្រូវបានតុលាការសម្រេចដាក់ពន្ធនាគារតាមអំណាច សាលក្រមស្ថាពរ និង សាលដីកាស្ថាពរ ចំនួន០៣ករណី រួមមានដូចខាងក្រោម:

# ករណី ទី០១

សំណុំរឿងព្រហ្មទណ្ឌលេខ:៥៨២ ចុះថ្ងៃទី១៤-៦-២០០៧ របស់សាលាឧទ្ធរណ៍ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **សំណាង** ហៅ **ចាន់** ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ ។

២-ឈ្មោះ [redacted] រតនៈ ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ ។

៣-ឈ្មោះ [redacted] **ធីធីន** ហៅ [redacted] **ធីន** ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ។

<u>ត្រូវជាប់ចោទពីបទ:</u> ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៧-៥-២០០៦ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស និងមាត្រា២០ នៃច្បាប់ ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ:៨៥"ខ" ចុះថ្ងៃទី២០-៣-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-<u>ផ្តន្ទាទោស:</u>

ក-ឈ្មោះ [redacted] **សំណាង** ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ

ខ-ឈ្មោះ [redacted] រតនៈ ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ

គ-ឈ្មោះ [redacted] **ធីធីន** ភេទប្រុស អាយុ២៦ឆ្នាំ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់០៥ឆ្នាំ គិតពីថ្ងៃផុតនៃការទទួលរងទោសក្នុងបណ្តាលនៃសាលក្រមមុន ពីបទ: ប្លន់ ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី០៧-៥-២០០៦ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-ឈ្មោះ [redacted] **ធីធីន** ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ

-ឈ្មោះ [redacted] ចាន់ណាក់ ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់០១ឆ្នាំ គិតពីថ្ងៃផុតទទួលទោស នៃការទទួលរងទោសក្នុង បណ្តានៃសាលក្រមមុនរួច ពីបទ: ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី០៧-៥-២០០៦ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ ។

៣-ឈ្មោះ [redacted] សុគា ហៅ ស្រីមុំ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់០១ឆ្នាំ គិតពីថ្ងៃផុតទទួលនៃការទទួលរងទោសក្នុងបណ្តានៃសាលក្រមមុនរួច ពីបទ: ទទួលផលចោរកម្ម ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី០៧-៥-២០០៦ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី១៦-០២-២០០៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២០-៣-២០០៧ ចំពោះមុខជនជាប់ចោទ៣រូប មេធាវី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ណាក់, [redacted] សុគា និងជនរងគ្រោះឈ្មោះ [redacted] បូរី។ ទុករយៈពេលប្តឹងទាស់ និងប្តឹង ឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ:៦៦"ខ" ចុះថ្ងៃទី២០-៤-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-តម្កល់សាលក្រមលេខ:៨៥"ខ" ចុះថ្ងៃទី២០-៣-២០០៧ ទុកដដែល តែកែប្រែត្រង់ចំណុច២ និង៣ ។

-ផ្តន្ទាទោសលើឈ្មោះ [redacted] ចាន់ណាក់ ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗ ចំនួន០១ឆ្នាំ(មួយឆ្នាំ) តែព្យួររយៈពេលសាកល្បង០៥ឆ្នាំ និងពិន័យជាប្រាក់មួយលានរៀល ពីបទៈ ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧-៥-២០០៦ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ និងមាត្រា៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ផ្តន្ទាទោសលើឈ្មោះ [redacted] សុខគា ហៅ ស្រីមុំ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗ ចំនួន០១ឆ្នាំ(មួយឆ្នាំ) តែទោសនេះត្រូវព្យួររយៈពេលសាកល្បង០៥ឆ្នាំ ពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧-៥-២០០៦ តាមមាត្រា៤៥ និងមាត្រា៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-សាលក្រមនេះ ជំនុំជម្រះ និង ប្រកាសជាសាធារណៈ នៅចំពោះមុខជនជាប់ចោទទាំង៥រូប មេធាវី កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។ ទុករយៈពេលប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញ សាដីកាព្រហ្មទណ្ឌស្ថាពរ លេខ:២០"ញ" ចុះថ្ងៃទី១២-០២-២០០៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧-៣-២០០៧ របស់ឈ្មោះ [redacted] **ធីធីន**, លឹម រតនៈ និង [redacted] **សំណាង** ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោល ដោយផ្ទុយគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌ លេខ:៦៦"ខ" ចុះថ្ងៃទី២០-៤-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការតទៅ ។

៣-បន្តការឃុំខ្លួនលើជនជាប់ចោទជាបន្ត ។

៤-សាលដីកានេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី១២-០២-២០០៩ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

<u>**ករណីទី០២**</u>

សំណុំរឿងព្រហ្មទណ្ឌលេខ:១២២១ ចុះថ្ងៃទី០៣-៦-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **សំណាង** ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ ។

២-ឈ្មោះ [redacted] រតនៈ ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ ។

៣-ឈ្មោះ [redacted] **ធីធីន** ហៅ [redacted] **ធីន** ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ។

<u>ត្រូវជាប់ចោទពីបទៈ</u> ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៩-៥-២០០៦ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ:១៣៧"ខ" ចុះថ្ងៃទី២១-១១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ផ្តន្ទាទោសលើឈ្មោះ [redacted] **សំណាង** ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] រតនៈ ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល០៥/...

ឆ្នាំ "ប្រាំឆ្នាំ" គិតបន្តពីសាលក្រមព្រហ្មទណ្ឌលេខ:៤៧"ខ" ចុះថ្ងៃទី២៧-កក្កដា-២០០៦ របស់តុលាការក្រុងភ្នំពេញ ពីបទ:ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៩-ឧសភា-២០០៦ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-ផ្តន្ទាទោសលើឈ្មោះ [redacted] ធីធីន ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល៦ឆ្នាំ"ប្រាំមួយឆ្នាំ" គិតបន្តពីសាលក្រមព្រហ្មទណ្ឌ លេខ:៤៧"ខ" ចុះថ្ងៃទី២៧-កក្កដា-២០០៦ របស់តុលាការក្រុងភ្នំពេញ ពីបទ:ប្លន់និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៩-ឧសភា-២០០៦ តាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

៣-ផ្តន្ទាទោសលើឈ្មោះ [redacted] ចាន់ណាក់ ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០១ឆ្នាំ"មួយឆ្នាំ" តែទោសនេះត្រូវព្យួរសាកល្បងរយៈពេល ០៥ ឆ្នាំ និងពិន័យជាប្រាក់ ចំនួន១.០០០.០០០រៀល"មួយលានរៀល" សម្រាប់ដាក់ចូលថវិការដ្ឋ ពីបទ: ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៩-ឧសភា-២០០៦ តាមមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ និងមាត្រា៧០ នៃ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ក្នុងករណីរឹងទទឹងមិនព្រមបង់ប្រាក់ពិន័យ រឺគ្មានប្រាក់បង់ត្រូវដាក់ គុកបង្ខំរូបកាយស្តីពីការអនុវត្តសាលក្រមព្រហ្មទណ្ឌ ។

៤-បង្គាប់ឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ២៤ឆ្នាំ, ឈ្មោះ លឹម រតន: ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ទីទីន រួមគ្នាសងសំណងរដ្ឋប្បវេណីទៅជនរងគ្រោះឈ្មោះ [redacted] ចាន់ សរុបចំនួន៣២៩៦$(បីពាន់ពីររយកៅសិបប្រាំមួយដុល្លាអាមេរិក) ចាប់តាំងពីសាលក្រមនេះចូលជាស្ថាពរក្នុងករណីរឹងទទឹងមិនព្រមសង រឺគ្មានប្រាក់សងត្រូវដាក់គុកបង្ខំរូបកាយតាមមាត្រា៧ ស្តីពីការដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៥-វត្ថុតាងរួមមាន: ទូរស័ព្ទដៃចាស់ៗ ចំនួន០៣គ្រឿង, នាឡិកាម៉ាក ឡុងស៊ីន ក្លែងក្លាយមួយគ្រឿង, ជញ្ចៀនលោហៈធាតុពណ៌លឿងមានដាំត្បូងពណ៌ស ចំនួនមួយវង់, កាបូបដៃពណ៌ខ្មៅចំនួនមួយ ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ។ ចំណែកកាំភ្លើងជរមួយដើម ត្រូវរឹបអូសបំផ្លាញចោល ។

៦-សាលក្រមនេះជំនុំជម្រះនិងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សំណាង, ឈ្មោះ [redacted] រតន:, ឈ្មោះ [redacted] ទីទីន មេធាវីការពារជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ណាក់ សម្រេចបើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**<u>ករណី ទី០៣</u>**

សំណុំរឿងព្រហ្មទណ្ឌលេខ:១២២៤ ចុះថ្ងៃទី០៣-៦-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ
ដែលមានជនជាប់ចោទៈ

១-ឈ្មោះ [redacted] **សំណាង** ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ ។

២-ឈ្មោះ [redacted] រតន: ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ ។

ជាប់ចោទពីបទ: ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៣-៥-២០០៦ ។

៣-ឈ្មោះ [redacted] **ធីធីន** ហៅ [redacted] **ធីន** ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ។

ជាប់ចោទពីបទ: ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី ០៣-៥-២០០៦ ។ /ll-

៤-ឈ្មោះ [redacted] សុខគា ហៅស្រីមុំ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ។

ជាប់ចោទពីបទ: ទទួលផលចោរកម្ម និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៣-៥-២០០៦ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌ លេខ:៨៧"ខ" ចុះថ្ងៃទី២៧-៧-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ផ្ដន្ទាទោសលើឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ២៨ឆ្នាំ និងឈ្មោះ [redacted] រតន: ភេទប្រុស អាយុ២៨ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយ:ពេល០៥ឆ្នាំ (ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០៥-៦-២០០៦ ពីបទ: ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៣-៥-២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៦នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-ផ្ដន្ទាទោសលើឈ្មោះ [redacted] ទីទីន ភេទប្រុស អាយុ២៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយ:ពេល០៦ឆ្នាំ(ប្រាំមួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០៥-៦-២០០៦ ពីបទ: ប្លន់និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៣-៥-២០០៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៦នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា២០ នៃច្បាប់ស្ដីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ ។

៣-ផ្ដន្ទាទោសលើឈ្មោះ [redacted] ចាន់ណាក់ ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយ:ពេល០១ឆ្នាំ(មួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន ពីបទ: ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៣-៥-២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា២០ នៃច្បាប់ស្ដីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

៤-ផ្ដន្ទាទោសលើឈ្មោះ [redacted] សុខគា ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយ:ពេល០១ឆ្នាំ(មួយឆ្នាំ) តែទោសនេះអនុវត្តក្នុងពន្ធនាគារ០២ខែ សល់ប៉ុន្មានត្រូវព្យួររយ:ពេលសាកល្បង០៥ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០៥-៦-២០០៦ ពីបទ: ទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៣-៥-២០០៦ ។

៥-ទុកសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងទាមទារសំណងនៅពេលក្រោយបាន ។

៦-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណ: ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សំណាង, ឈ្មោះ [redacted] រតន:, ឈ្មោះ [redacted] ទីទីន, ឈ្មោះ [redacted] សុខគា ចំពោះមុខមេធាវីការពារឲ្យជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ណាក់ និងដើមបណ្ដឹងរដ្ឋប្បវេណី។ សម្រេចបើកផ្លូវប្ដឹងទាស់និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ ពាក្យបណ្ដឹងសុំស្រាបទោស ចុះថ្ងៃទី២០-០១-២០១៤ របស់មេធាវី ។

-បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

-បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៤ ។

## នាពេលសវនាការ

-ទណ្ឌិតឈ្មោះ [redacted] សំណាង (អវត្តមាន)

-ទណ្ឌិតឈ្មោះ [redacted] ទីទីន (អវត្តមាន)

-មេធាវី [redacted] សិរី (វត្តមាន)

## តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា

សំណុំរឿងនេះ សុំស្រុបទោសឃើញថាមានលក្ខណៈត្រឹមត្រូវ។ ដូចនេះសុំសាលាឧទ្ធរណ៍ពិចារណាសម្រេចតាមច្បាប់ចុះ ។

-មេធាវី [redacted] សិរី បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] ទីទីន បានសុំស្រុបទោស ដែលមានសាលក្រម និងសាលដីកាស្ថាពរ បញ្ជាក់ជូនស្រាប់។ កូនក្តីខ្លួនទាំង២នាក់ ចាប់តាំងពីជាប់ក្នុងពន្ធនាគាររហូតមកអត់ដែល ប្រព្រឹត្តអ្វីខុសទេ គឺគោរពតាមបទបញ្ជាបានល្អណាស់ ខិតខំកសាងខ្លួន ដើម្បីឲ្យក្លាយទៅជាមនុស្សក្នុងសង្គម។ នៅពេលនេះ ខ្លួនសំណូមពរ សុំសាលាឧទ្ធរណ៍ស្រុបទោសឲ្យកូនក្តីខ្លួនតាមច្បាប់ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានឃើញសេចក្តីថ្លែងការណ៍របស់ទណ្ឌិត

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍
## យល់ឃើញថា

១-ពាក្យសុំស្រុបទោសបញ្ចូលគ្នា ចុះថ្ងៃទី២០-០១-២០១៨ របស់លោក [redacted] សុផង់ មេធាវីការពារឲ្យទណ្ឌិតឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] ទីទីន ធ្វើឡើងត្រឹមត្រូវតាមមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួល ជំនុំជម្រះបាន ។

២-ក-ទណ្ឌិតឈ្មោះ [redacted] សំណាង ត្រូវបានតុលាការសម្រេចផ្តន្ទាទោស តាមសាលក្រមផ្សេងគ្នា គឺ:

+បទ ប្លន់ប្រើអាវុធខុសច្បាប់ កាលពីថ្ងៃទី០៣-៥-២០០៦ ដែលសាលក្រមលេខ: ៤៧ "ខ" ចុះថ្ងៃទី២៧-៧-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានផ្តន្ទាទោស ចំនួន០៥ឆ្នាំ។

+បទ ប្លន់ប្រើអាវុធ កាលពីថ្ងៃទី១៩-៥-២០០៦ ដែលមានសាលក្រមលេខ:១៣៧"ខ" ចុះថ្ងៃទី២១-១១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានផ្តន្ទាទោស ចំនួន០៥ឆ្នាំ ។

+បទ ប្លន់ កាលពីថ្ងៃទី០៧-៥-២០០៦ ដែលមានសាលក្រមលេខ:៤៥"ខ" ចុះថ្ងៃទី១០-៣-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ បានផ្តន្ទាទោស ចំនួន០៥ឆ្នាំ ។

ខ-ទណ្ឌិតឈ្មោះ[redacted]ធីធីនត្រូវបានតុលាការសម្រេចផ្តន្ទាទោសតាមសាលក្រមផ្សេងគ្នាគឺ:

+បទ ប្លន់និងប្រើអាវុធ កាលពីថ្ងៃទី០៣-៥-២០០៦ ដែលមានសាលក្រមលេខ:៨៧"ខ" ចុះថ្ងៃទី២៧-៧-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ផ្តន្ទាទោស ចំនួន០៦ឆ្នាំ ។

+បទ ប្លន់និងប្រើអាវុធ កាលពីថ្ងៃទី១៩-៥-២០០៦ ដែលមានសាលក្រមលេខ: ១៣៧"ខ" ចុះថ្ងៃទី២១-១១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានផ្តន្ទាទោស០៦ឆ្នាំ។

+បទ ប្លន់ កាលពីថ្ងៃទី០៧-៥-២០០៦ ដែលមានសាលក្រមលេខ:៨៥"ខ" ចុះថ្ងៃទី ២០-៣-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ បានផ្តន្ទាទោស ចំនួន០៥ឆ្នាំ ។

៣-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: សំណុំរឿងនេះ សុំស្រូបទោសឃើញថា មានលក្ខណៈត្រឹមត្រូវ។ដូចនេះសុំសាលាឧទ្ធរណ៍ ពិចារណាសម្រេចតាមច្បាប់ចុះ ។

៤-មេធាវី [redacted] **សិរី** ការពារឲ្យទណ្ឌិតបានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនឈ្មោះ [redacted] សំណាង និងឈ្មោះ[redacted] ទីទីន បានសុំស្រូបទោស ដែលមានសាលក្រម និងសាលដីកាស្ថាពរ បញ្ជាក់ជូនស្រាប់។ កូនក្តីខ្លួនទាំង២នាក់ ចាប់តាំងពីជាប់ក្នុងពន្ធនាគាររហូតមកអត់ដែលប្រព្រឹត្តអ្វីខុសទេ គឺគោរពតាមបទបញ្ជាបានល្អណាស់ ខិតខំកសាងខ្លួន ដើម្បីឲ្យក្លាយទៅជាមនុស្សក្នុងសង្គម។ នៅពេល នេះ ខ្លួនសំណូមពរ សុំសាលាឧទ្ធរណ៍ស្រូបទោសឲ្យកូនក្តីខ្លួនតាមច្បាប់ ។

៥-តាមការយល់ឃើញខាងលើ គប្បីសាលាឧទ្ធរណ៍ អនុវត្តមាត្រា១៣៨នៃក្រមព្រហ្មទណ្ឌ ដោយស្រូបទោសពន្ធនាគារ :

ក-ចំពោះទណ្ឌិតឈ្មោះ[redacted]**សំណាង** : ទោស ចំនួន០៥ឆ្នាំ នៃសាលក្រមព្រហ្មទណ្ឌស្ថាពរ លេខ:១៣៧"ខ" ចុះថ្ងៃទី២១-១១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រូវស្រូបចូលក្នុងទោស០៥ឆ្នាំ នៃសាលដីកាស្ថាពរលេខ:២០"ញ" ចុះថ្ងៃទី១២-០២-២០០៩ របស់សាលាឧទ្ធរណ៍។ តាមមាត្រា៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ ។

ដូចនេះទណ្ឌិតឈ្មោះ[redacted]**សំណាង** ត្រូវអនុវត្តទោសក្នុងពន្ធនាគារសរុបចំនួន១០ឆ្នាំ។

ខ-ចំពោះទណ្ឌិតឈ្មោះ[redacted]**ធីធីន** : ទោស ចំនួន០៦ឆ្នាំ នៃសាលក្រមព្រហ្មទណ្ឌស្ថាពរ លេខ:១៣៧"ខ" ចុះថ្ងៃទី២១-១១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ និងទោស ចំនួន ០២ ឆ្នាំនៃសាលក្រមព្រហ្មទណ្ឌស្ថាពរ លេខ:៨៧"ខ" ចុះថ្ងៃទី២៧-៧-២០០៦ របស់សាលាដំបូង រាជធានីភ្នំពេញ ត្រូវស្រូបចូលទៅក្នុងទោស ចំនួន០៦ឆ្នាំ នៃសាលដីកាព្រហ្មទណ្ឌស្ថាពរ លេខ:២០"ញ" ចុះថ្ងៃទី១២-០២-២០០៩ របស់សាលាឧទ្ធរណ៍។ តាមមាត្រា៥០១ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ និងមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ ។

ដូចនេះ ទណ្ឌិតឈ្មោះ [redacted]**ធីធីន** ត្រូវអនុវត្តទោសក្នុងពន្ធនាគារ សរុប១០ឆ្នាំ ។

៦-ក-ឈ្មោះ [redacted] **សំណាង** បានឃុំខ្លួនតាំងពីថ្ងៃទី០៥-៦-២០០៦ គិតមកដល់ថ្ងៃទី ២០-១០-២០១៤ មានរយៈពេល០៨ឆ្នាំ៤ខែ១៥ថ្ងៃហើយ ។

ខ-ឈ្មោះ [redacted] នីនីន បានឃុំខ្លួនតាំងពីថ្ងៃទី០៥-៦-២០០៦ គិតមកដល់ថ្ងៃទី ២០-១០-២០១៤ មានរយៈពេល០៨ឆ្នាំ៤ខែ១៥ថ្ងៃហើយ ។

**ហេតុដូច្នេះទើបសម្រេច**

១-ទទួលពាក្យសុំស្របទោស ចុះថ្ងៃទី២០-០១-២០១៤ របស់លោក [redacted] **សុផង់** មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] **សំណាង** និងឈ្មោះ [redacted] **នីនីន** ទុកជាត្រឹមត្រូវតាម ទម្រង់ និងគតិច្បាប់ ។

២-ក-ចំពោះទណ្ឌិតឈ្មោះ [redacted] **សំណាង** :

-ទោស ចំនួន០៥ឆ្នាំ នៃសាលក្រមព្រហ្មទណ្ឌស្ពាព លេខ:១៣៧"ខ" ចុះថ្ងៃទី ២១-១១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រូវស្របចូលក្នុងទោស០៥ឆ្នាំ នៃសាលដីកាស្ពាពលេខ:២០"ញ" ចុះថ្ងៃទី១២-០២-២០០៩ របស់សាលាឧទ្ធរណ៍។ តាមមាត្រា៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ ។

ដូចនេះទណ្ឌិតឈ្មោះ [redacted] **សំណាង** ត្រូវអនុវត្តទោសក្នុងពន្ធនាគារសរុបចំនួន១០ឆ្នាំ។

ខ-ចំពោះទណ្ឌិតឈ្មោះ [redacted] **នីនីន** :

-ទោស ចំនួន០៦ឆ្នាំ នៃសាលក្រមព្រហ្មទណ្ឌស្ពាព លេខ:១៣៧"ខ" ចុះថ្ងៃទី ២១-១១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ និងទោស ចំនួន០២ឆ្នាំនៃសាលក្រមព្រហ្មទណ្ឌស្ពាព លេខ:៩៧"ខ" ចុះថ្ងៃទី២៧-៧-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រូវស្របចូលទៅក្នុងទោស ចំនួន០៦ឆ្នាំ នៃសាលដីកាព្រហ្មទណ្ឌស្ពាព លេខ:២០"ញ" ចុះថ្ងៃទី ១២-០២-២០០៩ របស់សាលាឧទ្ធរណ៍។ តាមមាត្រា៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និង មាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ ។

ដូចនេះ ទណ្ឌិតឈ្មោះ [redacted] **នីនីន** ត្រូវអនុវត្តទោសក្នុងពន្ធនាគារ សរុប១០ឆ្នាំ ។

៣-សាលដីកានេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី២០-១០-២០១៤ ទុកួសិទ្ធិឲ្យប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ភ្នំពេញ ថ្ងៃទី ១៤ ខែ ... ឆ្នាំ២០១៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

៤៨៩